# សេចក្ដីប្រកាស
# របស់សហប្រជាជាតិ
# ស្ដីពី
# អ្នកការពារសិទ្ធិមនុស្ស

ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួល
បន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

# អារម្ភកថា

នៅក្នុងឆ្នាំ១៩៩៨ មហាសន្និបាតអង្គការសហប្រជាជាតិ បាន អនុម័តសេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការសង្គមក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលត្រូវបានទទួលស្គាល់ជាសកល ។

សេចក្តីប្រកាសនេះ ត្រូវបានគេស្គាល់ជាទូទៅថា ជាសេចក្តី ប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស ។ គោលបំណងនៃសេចក្តី ប្រកាសនេះ គឺដើម្បីគាំទ្រ និងផ្តល់លទ្ធភាពដល់សកម្មភាពសន្តិភាព ដើម្បីសិទ្ធិមនុស្ស ទោះជាសកម្មភាពនោះ ធ្វើឡើងជាបុគ្គល ឬជា ក្រុមក្តី ។ រដ្ឋមានភារកិច្ចការពារជនទាំងអស់ដែលប្រើប្រាស់សិទ្ធិ ស្របច្បាប់ ដោយគ្មានការប្រើអំពើហឹង្សា ការគំរាមកំហែង ការ សងសឹក ការគាបសង្កត់ ឬការធ្វើតាមទំនើងចិត្ត ។

សេចក្តីប្រកាសនេះ គឺជាឫសគល់នៃសិទ្ធិទាំងឡាយ ដែលមាន ចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងបានធានាការ ពារនៅក្នុងសន្ធិសញ្ញានានាស្តីពីសិទ្ធិមនុស្សអន្តរជាតិ ដែលប្រទេស កម្ពុជាបានទទួលយក និងបានដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ហើយដែលជាផ្នែកនៃច្បាប់ជាតិ ។

សេចក្តីប្រកាសនេះបញ្ជាក់ឡើងវិញ និងថែងបន្ថែមទៅលើសិទ្ធិ និងបញ្ជាក់យ៉ាងច្បាស់អំពីការប្រើប្រាស់សិទ្ធិទាំងនេះចំពោះជនទាំងឡាយដែលការពារសិទ្ធិមនុស្ស ។ សេចក្តីប្រកាសនេះលើកកំពស់សិទ្ធិរបស់សកម្មជនការពារសិទ្ធិមនុស្សឧទាហរណ៍ដូចជា ៈ

សិទ្ធិជួប ឬប្រជុំដោយសន្តិវិធី សិទ្ធិបង្កើត ចូលជាសមាជិក និងចូលរួមនៅក្នុងអង្គការក្រៅរដ្ឋាភិបាល សមាគមឬក្រុមផ្សេងៗ ។

សិទ្ធិដឹង សិទ្ធិស្វែងរក សិទ្ធិបាន សិទ្ធិទទួល និងសិទ្ធិរក្សាព័ត៌មានស្តីពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន សិទ្ធិបោះពុម្ពផ្សាយ សិទ្ធិចែករំលែក ឬផ្សព្វផ្សាយមតិយោបល់ ព័ត៌មាន និងចំណេះដឹងស្តីពីសិទ្ធិ និងសេរីភាពទាំងនេះ និងសិទ្ធិទាញចំណាប់អារម្មណ៍របស់សាធារណៈជនចំពោះបញ្ហាទាំងនោះ ។

ចូលរួមនៅក្នុងសកម្មភាព ដោយសន្តិវិធីប្រឆាំងនឹងការរំលោភសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ។

សិទ្ធិស្វែងរក សិទ្ធិទទួល និងសិទ្ធិប្រើប្រាស់ធនធានផ្សេងៗ ក្នុងគោលបំណងជាក់លាក់ ដើម្បីលើកស្ទួយ និងការការពារសិទ្ធិមនុស្ស តាមរយៈមធ្យោបាយសន្តិវិធី ។

សិទ្ធិបញ្ជូនសំណើ ឬការរិះគន់ ដើម្បីធ្វើឱ្យប្រសើរឡើងថែមទៀតដល់ការប្រព្រឹត្តទៅរបស់ស្ថាប័ន ទីភ្នាក់ងារ និងអង្គការនានារបស់រដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការងារសាធារណៈ និងសិទ្ធិទាញការចាប់អារម្មណ៍ លើទិដ្ឋភាពការងាររបស់ខ្លួន ដែលអាចរារាំងដល់ការលើកស្ទួយ ការការពារ និងការទទួលបានសិទ្ធិមនុស្ស ។

អាណត្តិរបស់តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកអ្នកការពារសិទ្ធិមនុស្ស ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០០ ដើម្បីគាំទ្រដល់ការអនុវត្តសេចក្តីប្រកាសនេះ ។

ការិយាល័យឧត្តមស្នងការ
អង្គការសហប្រជាជាតិ
ទទួលបន្ទុកសិទ្ធិមនុស្ស
នៅកម្ពុជា
ខែកញ្ញា ឆ្នាំ២០០៦

# សេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវ របស់បុគ្គល ក្រុម និងអង្គការសង្គម ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ដែលត្រូវបានទទួលស្គាល់ជាសកល

អនុម័តដោយមហាសន្និបាត

តាមសេចក្តីសម្រេចចិត្តលេខ៥៣/១៤៤ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៩៨

***មហាសន្និបាត***

*បញ្ជាក់ឡើងវិញ*នូវសារសំខាន់នៃការអនុវត្តទិសដៅ និងគោលការណ៍នៃធម្មនុញ្ញសហប្រជាជាតិ ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានទាំងអស់សំរាប់មនុស្សទាំងអស់ នៅក្នុងប្រទេសទាំងអស់នៃពិភពលោក។

*បញ្ជាក់ឡើងវិញផងដែរ* នូវសារសំខាន់នៃសេចក្តីប្រកាស ជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ជាកត្តាមូលដ្ឋាននៃកិច្ចខិតខំជាអន្តរជាតិដើម្បីលើកស្ទួយការគោរព និងការអនុវត្តជា សកលនូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន និងសារសំខាន់នៃលិខិតុបករណ៍សិទ្ធិមនុស្សផ្សេងទៀតដែលអនុម័តក្នុងក្របខ័ណ្ឌសហប្រជាជាតិ និងក្នុងក្របខ័ណ្ឌទាំងឡាយនៅថ្នាក់តំបន់។

*សង្កត់ធ្ងន់ថា* សមាជិកទាំងអស់នៃសហគមន៍អន្តរជាតិ ត្រូវបំពេញកាតព្វកិច្ចដ៏ឱឡារិករបស់ខ្លួន ដោយរួមគ្នា និងដោយឡែកពីគ្នា ដើម្បីលើកស្ទួយ និងលើកទឹកចិត្តដល់ការគោរពសិទ្ធិមនុស្ស និងសេរីភាព មូលដ្ឋានសម្រាប់ទាំងអស់គ្នា ដោយគ្មានការប្រកាន់បែងចែកប្រភេទណាមួយ រួមមានការប្រកាន់បែងចែក ដែលផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ប្រភពសញ្ជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬឋានៈផ្សេងទៀតផង និង*បញ្ជាក់ឡើងវិញ* នូវសារសំខាន់ពិសេសនៃការធ្វើឱ្យសំរេចបាននូវសហប្រតិបត្តិការអន្តរជាតិ ដើម្បីបំពេញកាតព្វកិច្ចនេះ ស្របតាមធម្មនុញ្ញសហប្រជាជាតិ ។

*ទទួលស្គាល់* នូវតួនាទីសំខាន់នៃសហប្រតិបត្តិការអន្តរជាតិ និងការងារដ៏មានតម្លៃនៃបុគ្គល ក្រុម និងសមាគម ក្នុងការរួមចំណែកលុបបំបាត់ប្រកបដោយប្រសិទ្ធភាពនូវរាល់ការរំលោភសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់ប្រជាជាតិ និងបុគ្គល រួមមានពាក់ព័ន្ធទៅនឹងការរំលោភជាក់ស្តែង ឬដោយមានការរៀបចំទៅលើមហាជន ដូចជាការរំលោភដែលបណ្តាលមកពីនយោបាយអាប៉ា

ផែត រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អាណានិគមនិយម ការគាបសង្កត់ ឬការកាន់កាប់របស់បរទេស ការឈ្លានពាន ឬការគំរាមកំហែងអធិបតេយ្យជាតិ ឯកភាពជាតិ ឬបូរណភាពដែនដី និងដែលបណ្ដាលមកពីការបដិសេធមិនទទួលស្គាល់សិទ្ធិស្វ័យសម្រេចរបស់ប្រជាជាតិ និងសិទ្ធិប្រជាជាតិនីមួយៗក្នុងការប្រើប្រាស់អធិបតេយ្យភាពពេញលេញលើភោគទ្រព្យ និងធនធានធម្មជាតិរបស់ខ្លួន។

*ទទួលស្គាល់ថា* ទំនាក់ទំនងរវាងសន្តិភាព និងសន្តិសុខអន្តរជាតិ និងការអាស្រ័យផលនៃសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន *និងគិតថា* ការគ្មានសន្តិភាព និងសន្តិសុខអន្តរជាតិ មិនមែនជាការសំអាងសម្រាប់លើកលែងការមិនអនុវត្តឡើយ ។

*ប្រកាសបញ្ជាក់ឡើងវិញថា* សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានទាំងអស់ មានលក្ខណៈសកល មិនអាចចែកដាច់ពីគ្នា អាស្រ័យគ្នាទៅវិញទៅមក និងទាក់ទងគ្នាទៅវិញទៅមក ហើយត្រូវលើកស្ទួយ និងអនុវត្តក្នុងលក្ខណៈត្រឹមត្រូវ និងប្រកបដោយសមធម៌ដោយមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តសិទ្ធិ និងសេរីភាពនីមួយៗ ទាំងនោះឡើយ ។

*សង្កត់ធ្ងន់ថា* ការទទួលខុសត្រូវ និងករណីយកិច្ចមុនគេបង្អស់ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន គឺជាបន្ទុករបស់រដ្ឋ។

*ទទួលស្គាល់* សិទ្ធិ និងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងសមាគម ក្នុងការលើកស្ទួយការគោរព និងការបណ្តុះបណ្តាលឱ្យមានការយល់ដឹងអំពីសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាននៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។

***ប្រកាស :***

**មាត្រា ១**

ជនគ្រប់រូបមានសិទ្ធិដោយម្នាក់ៗ និងដោយរួមជាមួយអ្នកដទៃក្នុងការលើកស្ទួយ និងការខំប្រឹងប្រែងការពារនិងធ្វើឱ្យសម្រេចបាននូវសិទ្ធិមនុស្សនិងសេរីភាពមូលដ្ឋាននៅថ្នាក់ជាតិនិងថ្នាក់អន្តរជាតិ។

**មាត្រា ២**

១. រដ្ឋនីមួយៗ មានការទទួលខុសត្រូវ និងករណីយកិច្ចមុនគេបង្អស់ក្នុងការការពារ ការលើកស្ទួយ និងការអនុវត្តសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានទាំងអស់ ដោយការអនុម័តជាអាទិ៍នូវវិធានការ

ដែលអាចចាំបាច់ ដើម្បីបង្កើតរាល់ល័ក្ខខ័ណ្ឌចាំបាច់ក្នុងវិស័យសង្គមកិច្ច សេដ្ឋកិច្ច នយោបាយ និងវិស័យផ្សេងទៀត ព្រមទាំងការធានាខាងផ្លូវច្បាប់ដែលចាំបាច់ ដើម្បីធានាឱ្យជនគ្រប់រូបដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ អាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់នោះ ក្នុងការអនុវត្តជាក់ស្តែង ។

២. រដ្ឋនីមួយៗត្រូវអនុម័តវិធានការផ្លូវច្បាប់ រដ្ឋបាល និងវិធានការផ្សេងទៀតដែលចាំបាច់ ដើម្បីធានាថា សិទ្ធិ និងសេរីភាព ដែលចែងក្នុងសេចក្តីប្រកាសនេះត្រូវបានធានាប្រកបដោយប្រសិទ្ធភាព ។

## មាត្រា ៣

ច្បាប់ក្នុងប្រទេស ដែលស្របនឹងធម្មនុញ្ញសហប្រជាជាតិ និងកាតព្វកិច្ចអន្តរជាតិផ្សេងៗទៀតរបស់រដ្ឋក្នុងវិស័យសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានគឺជាក្របខ័ណ្ឌច្បាប់ដែលនៅក្នុងនោះ សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានត្រូវតែបានអនុវត្ត និងប្រើប្រាស់ ហើយដែលនៅក្នុងនោះ សកម្មភាពទាំងអស់ ដែលមានចែងក្នុងសេចក្តីប្រកាសនេះ ដើម្បីលើកស្ទួយ ការពារ និងធ្វើឱ្យសម្រេច ប្រកបដោយប្រសិទ្ធភាពនូវសិទ្ធិ និងសេរីភាពទាំងនេះ ត្រូវបានធ្វើឡើង ។

## មាត្រា ៤

គ្មានបទបញ្ញត្តិណាមួយនៅក្នុងសេចក្តីប្រកាសនេះ ត្រូវយកមកបកស្រាយតម្រូវឱ្យខូចខាត ឬជំទាស់គោលបំណង និងគោលការណ៍នៃធម្មនុញ្ញសហប្រជាជាតិ ឬតម្រូវឱ្យដាក់កំហិត ឬធ្វើបដិប្បញ្ញត្តិលើខទាំងឡាយនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស និង លិខិតុបករណ៍ និងការប្តេជ្ញាចិត្តអន្តរជាតិផ្សេងទៀត ដែលអនុវត្តក្នុងវិស័យនេះឡើយ ។

## មាត្រា ៥

ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានជនគ្រប់រូបមានសិទ្ធិដោយម្នាក់ឯង និងដោយរួមជាមួយអ្នកដទៃនៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ៖

(ក) ជួប ឬប្រជុំដោយសន្តិវិធី ។

(ខ) បង្កើត ចូលជាសមាជិក និងចូលរួមក្នុងអង្គការក្រៅរដ្ឋាភិបាល សមាគម ឬក្រុម ។

(គ) ឆ្លើយឆ្លងជាមួយអង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តររដ្ឋាភិបាល ។

## មាត្រា ៦

ជនគ្រប់រូប មានសិទ្ធិដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ ៖

(ក) ដឹង ស្វែងរក យកបាន ទទួល និងរក្សាព័ត៌មានស្ដីពីសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានទាំងអស់ រួមមានការទទួលបាននូវព័ត៌មានស្ដីពីរបៀបផ្ដល់អនុភាពដល់សិទ្ធិ និងសេរីភាពទាំងនោះផងក្នុងប្រព័ន្ធច្បាប់ តុលាការ ឬរដ្ឋបាលនៅក្នុងប្រទេស ។

(ខ) បោះពុម្ព ចែកចាយ ឬផ្សព្វផ្សាយដោយសេរី ទៅកាន់អ្នកដទៃទៀត អំពីទស្សនៈ ព័ត៌មាន និងការយល់ដឹងស្ដីពីសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានទាំងអស់ ដូចមានចែងក្នុងលិខិតុបករណ៍សិទ្ធិមនុស្ស និងលិខិតុករណ៍អន្តរជាតិផ្សេងទៀតដែលពាក់ព័ន្ធ ។

(គ) សិក្សា ពិភាក្សា បង្កើត និងមានមតិលើការអនុវត្ត ទាំងក្នុងច្បាប់ ទាំងក្នុងការអនុវត្តនូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានទាំងអស់ និងទាក់ទាញការយកចិត្តទុកដាក់ពីសាធារណៈជនទៅលើបញ្ហាទាំងនោះ តាមរយៈមធ្យោបាយទាំងនេះ និងមធ្យោបាយសមស្របផ្សេងទៀត ។

## មាត្រា ៧

ជនគ្រប់រូប មានសិទ្ធិដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ បណ្តុះ និងពិភាក្សាគំនិត និងគោលការណ៍ថ្មីៗស្តីពីសិទ្ធិមនុស្ស និងតស៊ូមតិឱ្យមានការព្រមទទួលយកគំនិតនិងគោលការណ៍ថ្មីៗ ។

## មាត្រា ៨

១. ជនគ្រប់រូប មានសិទ្ធិដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ ដោយគ្មានការរើសអើង ក្នុងការចូលរួមជាក់ស្តែងក្នុងការគ្រប់គ្រងប្រទេសរបស់ខ្លួន និងការដឹកនាំកិច្ចការសាធារណៈ ។

២. សិទ្ធិនេះរាប់បញ្ចូលជាអាទិ៍ សិទ្ធិដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ ដាក់ជូនស្ថាប័ន និងទីភ្នាក់ងាររដ្ឋាភិបាល និងអង្គការនានាទទួលបន្ទុកកិច្ចការសាធារណៈនូវការរិះគន់ និងសេចក្តីស្នើសុំនានា សម្រាប់កែលំអការប្រព្រឹត្តទៅនៃអង្គការ និងស្ថាប័នទាំងនោះ និងសិទ្ធិទាញការយកចិត្តទុកដាក់ទៅលើទិដ្ឋភាពការងារនៃអង្គការ និងស្ថាប័នទាំងនោះ ដែលអាចរារាំង ឬបង្កឧបសគ្គដល់ការលើកស្ទួយ ការការពារ និងការសម្រេចបាននូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ។

## មាត្រា ៩

១. ក្នុងការប្រើប្រាស់សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន រួមមានការលើកស្ទួយ និងការការពារសិទ្ធិមនុស្សដូចមានចែងក្នុងសេចក្តីប្រកាសនេះផង ជនគ្រប់រូបមានសិទ្ធិដោយម្នាក់ៗឯងក្តី និងដោយរួមជាមួយអ្នកដទៃក្តី ទទួលបានការដោះស្រាយប្រកបដោយប្រសិទ្ធភាព និងការការពារនៅពេលមានការរំលោភសិទ្ធិទាំងនោះ។

២. ដើម្បីសម្រេចទិសដៅនេះ ជនគ្រប់រូបដែលយល់ថាសិទ្ធិនិងសេរីភាពរបស់ខ្លួន ត្រូវបានរំលោភ មានសិទ្ធិប្តឹងដោយខ្លួនឯងផ្ទាល់ ឬតាមរយៈតំណាងស្របច្បាប់ និងមានសិទ្ធិឱ្យពិនិត្យពាក្យបណ្តឹងនោះភ្លាម ក្នុងសវនាការជាសាធារណៈ ចំពោះមុខតុលាការ ឬអាជ្ញាធរផ្សេងទៀត ដែលឯករាជ្យ មិនលំអៀង និងមានសមត្ថភាពដែលបង្កើតឡើងដោយច្បាប់ និងមានសិទ្ធិទទួលបានពីអាជ្ញាធរនោះ នូវសេចក្តីសម្រេចមួយស្របតាមច្បាប់ ដែលផ្តល់ការជួសជុលការខូចខាត រួមមានការទទួលបានសំណងជំងឺចិត្តផង បើមានការរំលោភសិទ្ធិ ឬសេរីភាពរបស់ជននោះ ព្រមទាំងការអនុវត្ត សេចក្តីសម្រេច និងសំណងជាយថាហេតុ ដោយគ្មានការពន្យារឱ្យយូរពេកទេ។

៣. ដើម្បីសម្រេចទិសដៅដដែលនេះ ជនគ្រប់រូប ដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ មានសិទ្ធិជាអាទិ៍ :

(ក) ប្តឹងអំពីគោលនយោបាយ និងសកម្មភាពរបស់មន្ត្រីម្នាក់ៗ និងស្ថាប័នរដ្ឋាភិបាល ចំពោះការរំលោភសិទ្ធិមនុស្ស និងសេរីភាព-មូលដ្ឋាន តាមរយៈបណ្តឹងទាមទារ ឬមធ្យោបាយសមស្របផ្សេងទៀតទៅអាជ្ញាធរតុលាការ រដ្ឋបាល ឬអង្គនីតិបញ្ញត្តិនៅក្នុងប្រទេស ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ដូចមានចែងក្នុងប្រព័ន្ធច្បាប់រដ្ឋនោះ ហើយអាជ្ញាធរទាំងនោះ ត្រូវធ្វើសេចក្តីសម្រេចលើពាក្យបណ្តឹងដោយឥតពន្យារពេលឱ្យយូរពេកទេ។

(ខ) ចូលរួមក្នុងសវនាការ នីតិវិធីជំនុំជំរះ និងការជំនុំជំរះក្តីជាសាធារណៈ ដើម្បីធ្វើការវិនិច្ឆ័យអំពីការប្រព្រឹត្តស្របតាមច្បាប់ជាតិ និងកាតព្វកិច្ច និងការប្តេជ្ញាចិត្តជាអន្តរជាតិ។

(គ) ផ្តល់ជំនួយផ្នែកច្បាប់ដែលមានលក្ខណៈវិជ្ជាជីវៈ ឬគំនិតប្រឹក្សា និងជំនួយពាក់ព័ន្ធផ្សេងទៀត ក្នុងការការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។

៤. ដើម្បីសម្រេចទិសដៅដដែលនេះនិងស្របតាមលិខិតុបករណ៍ និងនីតិវិធីអន្តរជាតិពាក់ព័ន្ធ ជនគ្រប់រូប ដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ មានសិទ្ធិចូលជួប និងឆ្លើយឆ្លងដោយគ្មានការ

រារាំង ជាមួយអង្គការអន្តរជាតិដែលមានសមត្ថកិច្ចទូទៅ ឬពិសេស សម្រាប់ទទួល និងពិនិត្យបណ្តឹងស្តីពីបញ្ហាសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។

៥. រដ្ឋត្រូវស៊ើបអង្កេតជាបន្ទាន់ និងដោយមិនលំអៀង ឬត្រូវធានាថា ការស៊ើបអង្កេតមួយនឹងធ្វើឡើង បើមានមូលដ្ឋានសមហេតុផលឱ្យជឿបានថា ការរំលោភសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានបានកើតឡើងក្នុងដែនដីស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

## មាត្រា ១០

ជនគ្រប់រូបមិនត្រូវចូលរួមរំលោភសិទ្ធិមនុស្សនិងសេរីភាពមូលដ្ឋាន ដោយទង្វើក្តី ឬដោយការខកខានមិនបានធ្វើ នៅពេលកាលៈទេសៈតម្រូវឱ្យធ្វើក្តី និងគ្មានជនណាម្នាក់ ត្រូវទទួលទណ្ឌកម្ម ឬការសងសឹកក្នុងប្រភេទណាមួយ ចំពោះការមិនព្រមធ្វើនោះឡើយ។

## មាត្រា ១១

ជនគ្រប់រូប មានសិទ្ធិដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ ប្រកបមុខរបរ ឬវិជ្ជាជីវៈ ស្របច្បាប់របស់ខ្លួន។ ជនគ្រប់រូប ដោយសារតែវិជ្ជាជីវៈរបស់ខ្លួន អាចប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់

មនុស្ស សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់អ្នកដទៃ ត្រូវគោរព សិទ្ធិនិងសេរីភាពទាំងនោះ និងត្រូវគោរពបទដ្ឋានជាតិ និងអន្តរជាតិ អំពីបទវិន័យ ឬក្រមសីលធមិខាងមុខរបរ និងវិជ្ជាជីវៈ។

**មាត្រា ១២**

១. ជនគ្រប់រូប មានសិទ្ធិដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ ចូលរួមក្នុងសកម្មភាពសន្តិវិធី ប្រឆាំងនឹងការរំលោភសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។

២. រដ្ឋត្រូវចាត់វាល់វិធានការចាំបាច់ ដើម្បីធានាឱ្យមាននូវការការពារពីអាជ្ញាធរមានសមត្ថកិច្ចចំពោះជនគ្រប់រូប ដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃប្រឆាំងនឹងអំពើហិង្សា ការគំរាមកំហែង ការសងសឹក ការរើសអើងជាអវិភូតជាក់ស្តែង ឬតាមផ្លូវច្បាប់ ការគៀបសង្កត់ ឬសកម្មភាពតាមអំពើចិត្តផ្សេងទៀតដោយសារតែការប្រើប្រាស់សិទ្ធិស្របច្បាប់របស់ខ្លួនដែលមានចែងក្នុងសេចក្តីប្រកាសនេះ។

៣. ពាក់ព័ន្ធរឿងនេះ ជនគ្រប់រូបមានសិទ្ធិ ដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ ក្នុងការទទួលសិទ្ធិទទួលបានការការពារប្រកបដោយប្រសិទ្ធភាព ស្របតាមច្បាប់ជាតិ ក្នុងការធ្វើប្រតិ

កម្មប្រឆាំង ឬជំទាស់ តាមមធ្យោបាយសន្តិវិធី ចំពោះសកម្មភាព និងទង្វើនានា រួមមានការខកខានមិនបានធ្វើរបស់រដ្ឋ ដែលនាំឱ្យមានការរំលោភសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានផង ព្រមទាំងអំពើហិង្សាប្រព្រឹត្តដោយក្រុម ឬដោយបុគ្គល ដែលធ្វើឱ្យប៉ះពាល់ដល់ការអាស្រ័យផលសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។

## មាត្រា ១៣

ជនគ្រប់រូប ដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ មានសិទ្ធិរៃអង្គាស ទទួល និងប្រើប្រាស់ធនធានសម្រាប់ទិសដៅជាក់លាក់ក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន តាមមធ្យោបាយសន្តិវិធី ស្របតាមមាត្រា ៣ នៃសេចក្តីប្រកាសនេះ។

## មាត្រា ១៤

១. រដ្ឋមានការទទួលខុសត្រូវក្នុងការចាត់វិធានការខាងនីតិបញ្ញត្តិ តុលាការ រដ្ឋបាល ឬវិធានការសមស្របដទៃទៀត ដើម្បីជំរុញឱ្យមនុស្សគ្រប់រូបដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួនយល់ដឹងអំពីសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គមកិច្ច និងសិទ្ធិវប្បធម៌របស់គេ។

២. មធ្យោបាយទាំងនោះ រួមមានជាអាទិ៍ ៖

(ក) ការបោះពុម្ព និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយ នូវច្បាប់ និងបទបញ្ញត្តិជាតិ ព្រមទាំងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិសំខាន់ៗដែលពាក់ព័ន្ធ។

(ខ) លទ្ធភាពទទួលបានពេញលេញ និងស្មើភាព នូវឯកសារអន្តរជាតិក្នុងវិស័យសិទ្ធិមនុស្ស រួមមានរបាយការណ៍ទៀងទាត់តាមកាលកំណត់ ដែលរដ្ឋផ្ញើ និងផ្ញើជូនស្ថាប័ននានា ដែលបង្កើតឡើងស្របតាមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលរដ្ឋចូលជាភាគីផង ព្រមទាំងសំណុំរឿងសង្ខេបស្តីពីកិច្ចពិភាក្សា និងរបាយការណ៍ផ្លូវការរបស់ស្ថាប័នទាំងនេះ។

៣. យោងទៅតាមករណីសមស្រប រដ្ឋត្រូវធានា និងគាំទ្រដល់ការបង្កើត និងពង្រីកស្ថាប័នជាតិ ឯករាជ្យបន្ថែម ទោះស្ថាប័នទាំងនេះជាការិយាល័យប្រជាពលរដ្ឋក្តី ជាគណៈកម្មការសិទ្ធិមនុស្សក្តី ឬជាស្ថាប័នជាតិតាមទម្រង់ណាមួយក្តី ដើម្បីលើកស្ទួយ និងការពារ-សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានក្នុងដែនដីស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

## មាត្រា ១៥

រដ្ឋមានការទទួលខុសត្រូវចំពោះការលើកស្ទួយ និងការសម្រួលដល់ការបង្រៀនសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន នៅគ្រប់កម្រិតសិក្សា និងត្រូវធានាថា អ្នកទាំងឡាយដែលទទួលខុសត្រូវក្នុងការបណ្តុះបណ្តាលមេធាវី មន្ត្រីអនុវត្តច្បាប់ បុគ្គលិកនៃកងកម្លាំងប្រដាប់អាវុធ និងមន្ត្រីសាធារណៈ ត្រូវបញ្ចូលផ្នែកសមស្រប នៃការបង្រៀនសិទ្ធិមនុស្ស ទៅក្នុងកម្មវិធីហ្វឹកហ្វឺនរបស់ពួកគេ។

## មាត្រា ១៦

បុគ្គល អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធ មានតួនាទីសំខាន់ក្នុងការរួមចំណែកធ្វើឱ្យសាធារណៈជនយល់ដឹងកាន់តែច្រើនឡើង អំពីបញ្ហាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានទាំងអស់ តាមរយៈសកម្មភាពនានា ដូចជាការអប់រំ ការហ្វឹកហ្វឺន និងការស្រាវជ្រាវក្នុងវិស័យទាំងនេះ ដើម្បីពង្រឹងបន្ថែមជាអាទិ៍ ការយោគយល់ ការអត់ឱនឱ្យគ្នា សន្តិភាព និងទំនាក់ទំនងជាមិត្តភាពក្នុងចំណោមប្រជាជាតិ និងក្រុមពូជសាសន៍ និងសាសនាទាំងអស់ ដោយយកចិត្តទុកដាក់អំពីសាវតាសង្គម និងសហគមន៍ ដែលបុគ្គលអង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នទាំងនោះ ធ្វើសកម្មភាព។

## មាត្រា ១៧

ក្នុងការប្រើប្រាស់សិទ្ធិ និងសេរីភាព ដែលមានចែងក្នុងសេចក្តីប្រកាសនេះ ជនគ្រប់រូប ដោយម្នាក់ៗឯង និងដោយរួមជាមួយអ្នកដទៃ អាចស្ថិតក្រោមការដាក់កម្រិតព្រំដែនបាន លុះត្រាតែការដាក់កម្រិតព្រំដែនទាំងនេះ ស្របតាមកាតព្វកិច្ចអន្តរជាតិពាក់ព័ន្ធ និង-មានកំណត់ដោយច្បាប់ និងសម្រាប់តែធានាឱ្យមានការទទួលស្គាល់ និងគោរពសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ និងសម្រាប់តែតម្រូវដល់ការចាំបាច់ខាងសីលធម៌ សណ្តាប់ធ្នាប់សាធារណៈនិងសុខុមាលភាពទូទៅក្នុងសង្គមប្រជាធិបតេយ្យ ។

## មាត្រា ១៨

១. ជនគ្រប់រូប មានករណីកិច្ចចំពោះសហគមន៍ និងក្នុងក្របខ័ណ្ឌសហគមន៍ ដែលជាកន្លែងតែមួយគត់ ដែលអាចឱ្យមានការអភិវឌ្ឍន៍ពេញលេញ និងដោយសេរីនូវបុគ្គលិកលក្ខណៈរបស់ខ្លួន ។

២. បុគ្គល ក្រុម ស្ថាប័ន និងអង្គការក្រៅរដ្ឋាភិបាលនានា មានតួនាទីសំខាន់ និងការទទួលខុសត្រូវមួយ ក្នុងការរក្សាការពារលទ្ធិប្រជាធិបតេយ្យ ក្នុងការលើកស្ទួយសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន និងក្នុងការធ្វើវិភាគទានជួយលើកស្ទួយ និងធ្វើឱ្យជឿនលឿនទៅមុខនូវសង្គម ស្ថាប័ន និងដំណើរការប្រជាធិបតេយ្យ ។

៣. បុគ្គល ក្រុម ស្ថាប័ននិងអង្គការក្រៅរដ្ឋាភិបាលក៏មានតួនាទីសំខាន់ និងការទទួលខុសត្រូវមួយផងដែរ ក្នុងការធ្វើវិភាគទានតាមករណីសមស្រប ជួយលើកស្ទួយសិទ្ធិរបស់ជនគ្រប់រូប ក្នុងការទទួលបាននូវសណ្ដាប់ធ្នាប់សង្គម និងអន្តរជាតិ ដែលក្នុងនោះ សិទ្ធិ និងសេរីភាព ដូចមានចែងក្នុងសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងលិខិតុបករណ៍សិទ្ធិមនុស្សផ្សេងទៀត អាចសម្រេចបានយ៉ាងពេញលេញ ។

## មាត្រា ១៩

គ្មានបទបញ្ញត្តិណាមួយក្នុងសេចក្ដីប្រកាសនេះ ត្រូវយកមកបកស្រាយសម្រាប់ឱ្យបុគ្គល ក្រុម អង្គការសង្គម ឬរដ្ឋណាមួយមានសិទ្ធិធ្វើសកម្មភាព ឬប្រព្រឹត្តអំពើណាមួយសំដៅបំផ្លិចបំផ្លាញសិទ្ធិ និងសេរីភាពដែលមានចែងក្នុងសេចក្ដីប្រកាសនេះឡើយ ។

## មាត្រា ២០

គ្មានបទបញ្ញត្តិណាមួយក្នុងសេចក្ដីប្រកាសនេះ ត្រូវយកមកបកស្រាយ សម្រាប់អនុញ្ញាតឱ្យរដ្ឋគាំទ្រ និងលើកស្ទួយសកម្មភាពរបស់បុគ្គល ក្រុមបុគ្គល ស្ថាប័ន ឬអង្គការក្រៅរដ្ឋាភិបាល ដែលផ្ទុយពីបទបញ្ញត្តិនៃធម្មនុញ្ញសហប្រជាជាតិឡើយ ។

--------//--------